**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៣៧...អនក្រ.បក

* * * * *

# អនុក្រឹត្យ

# ស្តីពី

# ការទទួលស្គាល់ វិទ្យាស្ថានឯកទេសសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

* * * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក. ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពី លក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

# សម្រេច

## មាត្រា ១.-

ត្រូវបានទទួលស្គាល់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា វិទ្យាស្ថានឯកទេសសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (Institute of Specialized Economics and Finance) សរសេរកាត់ជាភាសាខ្មែរ "វ.ឯ.ស.ហ" និងសរសេរកាត់ជាភាសាអង់គ្លេស "ISEF" ។

## មាត្រា ២.-

វិទ្យាស្ថានឯកទេសសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានទីតាំងស្ថិតនៅ អគារលេខ ៤៤- ៤៦ និងអគារលេខ ៦០ ផ្លូវ ៣១៣ សង្កាត់បឹងកក់ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ វិទ្យាស្ថាននេះ ស្ថិតនៅក្រោមឱវាទ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

## មាត្រា ៣.-

វិទ្យាស្ថានឯកទេសសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្វើការបណ្តុះបណ្តាលកម្រិត បរិញ្ញាបត្ររងរហូតដល់បរិញ្ញាបត្រជាន់ខ្ពស់ លើមហាវិទ្យាល័យ ពីរ និង មជ្ឈមណ្ឌល មួយ៖

១- មហាវិទ្យាល័យបច្ចេកវិទ្យាព័ត៌មាន និងភាសា

២- មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងសេដ្ឋកិច្ច

៣- មជ្ឈមណ្ឌលទីផ្សារមូលបត្រ និងសិក្សាស្រាវជ្រាវ

វិទ្យាស្ថានឯកទេសសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំកម្មវិធីសិក្សាលម្អិតតាមកម្រិត និងមុខជំនាញ ដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា មុននឹងចាប់ផ្តើមដំណើរការបណ្តុះបណ្តាល។ ទៅអនាគត វិទ្យាស្ថាននេះ អាចបើកសាខាមហាវិទ្យាល័យថ្មី មុខជំនាញថ្មី កម្រិត ឬ ថ្នាក់ថ្មី ប្រភេទបណ្តុះបណ្តាលថ្មី ប្តូរឈ្មោះ ឬ ទីតាំងថ្មី ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពី ក្រសួងអប់រំ យុវជន និងកីឡា ។

## មាត្រា ៤.-

វិទ្យាស្ថានឯកទេសសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវមានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេច លើគោលនយោបាយ ផែនការអភិវឌ្ឍ កម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត ។ តួនាទី ភារកិច្ច របនាសម្ព័ន្ធគ្រប់គ្រង និងការប្រព្រឹត្តទៅនៃ វិទ្យាស្ថានឯកទេសសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលរបស់វិទ្យាស្ថាន និង មានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

## មាត្រា ៥.-

នាយកវិទ្យាស្ថានឯកទេសសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ច ៖

-ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងវិទ្យាស្ថាន និងធានាឲ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ។

-ទទួលខុសត្រូវក្នុងការជ្រើសរើសនិស្សិតឲ្យចូលរៀន និងទទួលនិស្សិតឲ្យសិក្សាបន្ត តាមកម្មវិធីសិក្សារបស់វិទ្យាស្ថាន ។

-គោរព និងអនុវត្តតាមការណែនាំ និងបទដ្ឋាន ដែលពាក់ព័ន្ធនឹងការងារបណ្តុះបណ្តាលរបស់ក្រសួងអប់រំ យុវជន និងកីឡា និងច្បាប់របស់រាជរដ្ឋាភិបាល សំដៅធានាគុណភាពអប់រំ ។

-រៀបចំតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រងវិទ្យាស្ថាន និងវិធានផ្ទៃក្នុង សម្រាប់ការគ្រប់គ្រងការសិក្សា ឲ្យបានច្បាស់លាស់ ស្របតាមគោលការណ៍ ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

-ធ្វើរបាយការណ៍ប្រចាំឆ្នាំ អំពីការងារបណ្តុះបណ្តាល មកក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់ ។

## មាត្រា ៦.-

និស្សិតវិទ្យាស្ថានឯកទេសសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានរៀនចប់កម្មវិធីសិក្សា និងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងមុខជំនាញដែលបានសិក្សា។ សញ្ញាបត្រនេះ ត្រូវផ្តល់ឲ្យដោយវិទ្យាស្ថានឯកទេសសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីវិទ្យាស្ថានឯកទេសសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និងកីឡា ។

## មាត្រា ៧.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីរដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រុមប្រឹក្សាភិបាល រួមទាំងនាយកនៃវិទ្យាស្ថានឯកទេសសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុក អនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១១

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ